ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ០៣៤ សរ.ណន

# សេចក្ដីណែនាំ

## ស្ដីពី

## ការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូន គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក

ចាប់តាំងពីបានប្រកាសចូលកាន់តំណែង ក្រសួងមហាផ្ទៃបានពិនិត្យឃើញថា គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក បានខិតខំ និងសហការក្នុងជួរគណៈអភិបាលអនុវត្តនូវតួនាទី ភារកិច្ច របស់ខ្លួន ស្របតាមគោលការណ៍នៃលិខិតបទដ្ឋានដែលបានកំណត់ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និង សម្រេចបានលទ្ធផលគួរជាទីមោទនៈ ។

ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានដែលកំណត់អំពីតួនាទី ភារកិច្ច ទំនាក់ទំនងការងារ របៀបរបបធ្វើការងាររវាងក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់អំពីដំណើរការរៀបចំឡើងវិញជាជំហានៗ នូវរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចសម្រាប់រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ លើមូលដ្ឋាននេះ ក្រសួងមហាផ្ទៃ បានដំណើរការធ្វើសមាហរណកម្មមន្ត្រីរាជការ ដែលកំពុងបម្រើការងារនៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធថ្មី ស្របទៅតាម គោលការណ៍កំណត់ ។

**មាត្រា៣៣ មាត្រា ៩០ និងមាត្រា១៩១** នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក បានកំណត់ថា **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញ សេចក្ដីណែនាំអំពីការបែងចែកភារកិច្ចដល់អភិបាល អភិបាលរងខេត្ត ក្រុង ស្រុក និងរបៀបរបបអនុវត្តភារកិច្ច ដែលបានបែងចែកនោះ** ។

លើមូលដ្ឋាននៃមាត្រាខាងលើ និងដើម្បីធានាពង្រឹងនូវសាមគ្គីភាពផ្ទៃក្នុង និងស្មារតីទទួលខុសត្រូវក្នុងការងារ ក៏ដូចជាការពង្រឹងរចនាសម្ព័ន្ធថ្មីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យក្លាយជាស្ថាប័នរឹងមាំមួយ ដែលមានលទ្ធភាពក្នុងការជំរុញការអភិវឌ្ឍ និងផ្តល់សេវាកម្មនានា ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំអំពីទំនាក់ទំនងការងាររវាងក្រុមប្រឹក្សានិងគណៈអភិបាល និងការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក ដូចខាងក្រោម ៖

## I. គណៈអភិបាលខេត្ត

### ក. ការបែងចែកតួនាទី ភារកិច្ចក្នុងជួរគណៈអភិបាលខេត្ត

ផ្អែកតាមរចនាសម្ព័ន្ធថ្មីរបស់សាលាខេត្ត គណៈអភិបាលខេត្ត ត្រូវប្រជុំពិភាក្សា ដើម្បីបែងចែកភារកិច្ចដល់អភិបាលខេត្ត និងអភិបាលរងខេត្ត ដើម្បីទទួលខុសត្រូវជួយទៅលើការងារនៅតាមទីចាត់ការ ការិយាល័យ និងកិច្ចការនៃមន្ទីរ វិស័យនានាដែលពាក់ព័ន្ធ ហើយសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន ។

អភិបាលខេត្តត្រូវធ្វើការបែងចែកភារកិច្ចដល់អភិបាលរងខេត្តក្នុងគណៈអភិបាលរបស់ខ្លួនឱ្យជួយការងារនៅក្នុងរដ្ឋបាលខេត្ត។ អភិបាលរងខេត្ត ដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលខេត្ត លើភារកិច្ចនានាដែលបានប្រគល់ ហើយត្រូវរួមជាមួយអភិបាលខេត្តដើម្បីទទួលខុសត្រូវអំពីការសម្រេច និងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន។

**ការបែងចែកភារកិច្ចខាងលើ អាចត្រូវបានអនុវត្តដូចខាងក្រោម ៖**

**១. ការបែងចែកភារកិច្ចសម្រាប់ខេត្តដែលមានគណៈអភិបាលចំនួន ០៥រូប ៖**

- **អភិបាលខេត្ត** ទទួលបន្ទុកដឹកនាំការងាររួម និងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ កិច្ចការគ្រប់គ្រងធនធានមនុស្ស ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការមុខងារសាធារណៈ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលខេត្ត លើកិច្ចការព័ត៌មាន កិច្ចការវេទិកាសាធារណៈ កិច្ចការស្ថិតិនិងអត្រានុកូលដ្ឋាន កិច្ចការនារីនិងកុមារ កិច្ចការអប់រំ យុវជន និងកីឡា វប្បធម៌ ធម្មការនិងសាសនា កិច្ចការតុលាការនិងពន្ធនាគារ កិច្ចការទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល គណបក្សនយោបាយ សមាគម និងកិច្ចការសិទ្ធិមនុស្ស។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលខេត្ត លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កិច្ចការធនាគាររតនាគារ ពន្ធដារ គយនិងរដ្ឋាករ កិច្ចការសាខាកាំកុងត្រូល និងកិច្ចការលទ្ធកម្មសាធារណៈ ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលខេត្ត លើកិច្ចការផែនការ វិនិយោគ កិច្ចការទេសចរណ៍ សុខាភិបាល អនាម័យនិងប្រឆាំងជំងឺឆ្លង កិច្ចការបរិស្ថាន និងអភិរក្សឧទ្យានជាតិ កិច្ចការគ្រប់គ្រងកាកសំណល់រឹងនិងរាវ កិច្ចការសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កិច្ចការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ កិច្ចការអភិវឌ្ឍន៍ជនបទ កិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ និងកិច្ចការព្រំដែន (ចំពោះខេត្តជាប់ព្រំដែន)។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលខេត្ត លើកិច្ចការសាធារណការនិងដឹកជញ្ជូន កិច្ចការនគរូបនីយកម្ម សំណង់និងសុរិយោដី កិច្ចការទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច កិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ កិច្ចការកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល កិច្ចការពាណិជ្ជកម្ម កិច្ចការឧស្សាហកម្ម រ៉ែ និងថាមពល ទឹកស្អាត និងអង្គភាពអគ្គិសនី កិច្ចការធនធានទឹក ឧតុនិយម និងធារាសាស្ត្រ កិច្ចការប្រៃសណីយ៍ និងទូរគមនាគមន៍។

**២-ការបែងចែកភារកិច្ចសម្រាប់ខេត្តដែលមានគណៈអភិបាលចំនួន ០៦រូប :**

- **អភិបាលខេត្ត** ទទួលបន្ទុកដឹកនាំការងាររួម និងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន និង ជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលខេត្ត លើកិច្ចការនារី និងកុមារ កិច្ចការវប្បធម៌ ធម្មការ និង សាសនា កិច្ចការព័ត៌មាន កិច្ចការវេទិកាសាធារណៈ កិច្ចការទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល គណបក្សនយោបាយ សមាគម កិច្ចការសិទ្ធិមនុស្ស កិច្ចការស្ថិតិនិងអត្រានុកូលដ្ឋាន កិច្ចការទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលខេត្ត លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កិច្ចការធនាគារ រតនាគារ ពន្ធដារ គយនិងរដ្ឋាករ កិច្ចការសាខាកាំកុងត្រូល និងកិច្ចការលទ្ធកម្មសាធារណៈ ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលខេត្ត លើកិច្ចការផែនការ វិនិយោគ អភិវឌ្ឍន៍ជនបទ ទេសចរណ៍ កិច្ចការទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ កិច្ចការបរិស្ថាន និងអភិរក្សឧទ្យានជាតិ កិច្ចការគ្រប់គ្រងកាកសំណល់រឹងនិងរាវ កិច្ចការសុខាភិបាល អនាម័យនិងប្រឆាំងជំងឺឆ្លង កិច្ចការសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា កិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ និងកិច្ចការព្រំដែន (ចំពោះខេត្តជាប់ព្រំដែន)។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលខេត្ត លើកិច្ចការសាធារណការ និងដឹកជញ្ជូន កិច្ចការនគរូបនីយកម្ម សំណង់និងសុរិយោដី កិច្ចការកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល កិច្ចការពាណិជ្ជកម្ម កិច្ចការឧស្សាហកម្ម រ៉ែនិងថាមពល ទឹកស្អាត និងអង្គភាពអគ្គិសនី កិច្ចការធនធានទឹក ឧតុនិយម និងធារាសាស្ត្រ និងកិច្ចការប្រៃសណីយ៍និងទូរគមនាគមន៍ ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលខេត្ត លើការងារគ្រប់គ្រងធនធានមនុស្ស ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការមុខងារសាធារណៈ កិច្ចការអប់រំ យុវជន និងកីឡា កិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ និងកិច្ចការតុលាការនិងពន្ធនាគារ ។

**៣. ការបែងចែកភារកិច្ចសម្រាប់ខេត្តដែលមានគណៈអភិបាលចំនួន ០៧រូប :**

- **អភិបាលខេត្ត** ទទួលបន្ទុកដឹកនាំការងាររួម និងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលខេត្ត លើកិច្ចការនារី និងកុមារ កិច្ចការវប្បធម៌ ធម្មការ និងសាសនា ទេសចរណ៍ កិច្ចការព័ត៌មាន និងកិច្ចការទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលខេត្ត លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កិច្ចការធនាគារ រតនាគារ ពន្ធដារ គយនិងរដ្ឋាករ កិច្ចការសាខាកាំកុងត្រូល និងកិច្ចការលទ្ធកម្មសាធារណៈ ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលខេត្ត លើកិច្ចការវេទិកាសាធារណៈ កិច្ចការស្ថិតិនិងអត្រានុកូលដ្ឋាន កិច្ចការតុលាការ និងពន្ធនាគារ កិច្ចការទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច កិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ កិច្ចការទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល គណបក្សនយោបាយ សមាគម និងកិច្ចការសិទ្ធិមនុស្ស ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលខេត្ត លើកិច្ចការផែនការ វិនិយោគ កិច្ចការអភិវឌ្ឍន៍ជនបទ កិច្ចការសង្គមកិច្ច អតីតយុទ្ធជននិង យុវនីតិសម្បទា កិច្ចការបរិស្ថាននិងអភិរក្សឧទ្យានជាតិ កិច្ចការគ្រប់គ្រងកាកសំណល់រឹងនិងរាវ កិច្ចការសុខាភិបាល អនាម័យនិងប្រឆាំងជំងឺឆ្លង កិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ និងកិច្ចការព្រំដែន ( ចំពោះខេត្តជាប់ព្រំដែន ) ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលខេត្ត លើកិច្ចការសាធារណការ និងដឹកជញ្ជូន កិច្ចការនគរូបនីយកម្ម សំណង់និងសុរិយោដី កិច្ចការកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល កិច្ចការធនធានទឹក ឧតុនិយម និងធារាសាស្ត្រ កិច្ចការពាណិជ្ជកម្ម វិស័យឧស្សាហកម្ម រ៉ែនិងថាមពល ទឹកស្អាត និងអង្គភាពអគ្គិសនី កិច្ចការប្រៃសណីយ៍និងទូរគមនាគមន៍ ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលខេត្ត លើកិច្ចការគ្រប់គ្រងធនធានមនុស្ស ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការមុខងារសាធារណៈ និងកិច្ចការអប់រំ យុវជន និងកីឡា ។

ផ្អែកតាមការបែងចែកតួនាទី ភារកិច្ចខាងលើ អភិបាលខេត្តត្រូវពិភាក្សាដើម្បីចាត់អភិបាលរងខេត្តទៅក្នុងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខ្លួន ឱ្យបានសមស្របតាមសមត្ថភាព បទពិសោធន៍ ជំនាញ និងការបែងចែកភារកិច្ច ដូចបានកំណត់ខាងលើផងដែរ ។/.

ក្រៅពីភារកិច្ចដែលបានបែងចែកដល់អភិបាលរងខេត្ត អភិបាលអាចប្រគល់ភារកិច្ចបន្ថែមជូនអភិបាលរងទៅតាមសំណូមពរការងារជាក់ស្តែងរបស់រដ្ឋបាលខេត្តនីមួយៗ ។

ក្នុងករណីដែលមានការផ្លាស់ប្តូរអភិបាលឬអភិបាលរងខេត្ត អភិបាលឬអភិបាលរងខេត្តចូលកាន់តំណែងត្រូវបន្តអនុវត្តភារកិច្ចពីអភិបាលឬអភិបាលរងខេត្ត ដែលត្រូវបានផ្លាស់ចេញ ឬទទួលភារកិច្ចតាមការពិភាក្សាបែងចែករបស់គណៈអភិបាល បន្ទាប់ពីមានការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន។

ក្រោយពីបានពិនិត្យ ពិភាក្សាក្នុងគណៈអភិបាលរួចហើយ អភិបាលខេត្ត ត្រូវរៀបចំសេចក្តីព្រាង**សេចក្តីសម្រេច**ស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលខេត្ត ដើម្បីស្នើសុំការពិនិត្យ សម្រេចពីក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ។ ផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សា អភិបាលខេត្ត ត្រូវចុះហត្ថលេខាលើសេចក្តីសម្រេច ស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលខេត្ត ( **ដូចមានគំរូជូនភ្ជាប់** ) ។

ក្នុងករណីក្រុមប្រឹក្សាមិនឯកភាពទៅលើសេចក្តីព្រាងសេចក្តីសម្រេចដែលស្នើឡើង គណៈអភិបាលត្រូវយកមតិយោបល់របស់ក្រុមប្រឹក្សាមកពិនិត្យ ពិចារណា ដើម្បីកែសម្រួលតាមសេចក្តីព្រាងសេចក្តីសម្រេចនោះឱ្យបានស្របទៅតាមស្មារតីប្រជុំក្រុមប្រឹក្សា។ ប៉ុន្តែប្រសិនបើ គណៈអភិបាលយល់ឃើញថា មតិយោបល់របស់ក្រុមប្រឹក្សា មិនមានលក្ខណៈសមស្រប ហើយគណៈអភិបាលពុំអាចកែសម្រួលបានទេ អភិបាលខេត្ត ត្រូវរាយការណ៍បំភ្លឺជូនក្រុមប្រឹក្សារបស់ខ្លួន អំពីមូលហេតុដែលពុំអាចកែសម្រួលបាន ដើម្បីស្នើសុំការសម្រេចពីក្រុមប្រឹក្សាជាថ្មីម្តងទៀត។

សេចក្តីសម្រេចរបស់អភិបាលខេត្ត ត្រូវបញ្ជូនមកក្រសួងមហាផ្ទៃ ដើម្បីដាក់ជូនរដ្ឋមន្ត្រី ពិនិត្យសម្រេចផ្តល់អនុលោមភាព ។ ករណីក្រសួងមហាផ្ទៃពិនិត្យឃើញថា សេចក្តីសម្រេចរបស់ខេត្ត មិនមានលក្ខណៈសមស្រប ឬមិនមានមូលដ្ឋានគតិយុត្តត្រឹមត្រូវ ក្រសួងមហាផ្ទៃអាចបញ្ជូនសេចក្តីសម្រេចនោះទៅរដ្ឋបាលខេត្ត ដោយភ្ជាប់ជាមួយនូវមតិយោបល់ និងអនុសាសន៍ជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យអភិបាលខេត្តធ្វើការកែសម្រួលសេចក្តីសម្រេចនោះឡើងវិញ ។ អភិបាលខេត្ត ត្រូវធ្វើការកែសម្រួលសេចក្តីសម្រេចរបស់ខ្លួន និងត្រូវចុះហត្ថលេខារួចបញ្ជូនមកក្រសួងមហាផ្ទៃ ដើម្បីផ្តល់អនុលោមភាពជាថ្មី ។ អភិបាលខេត្ត ត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន អំពីការកែសម្រួលនេះ ។

នៅពេលមានការបំពេញបន្ថែម ឬកែសម្រួលភារកិច្ចរបស់អភិបាលរងណាមួយ ឬរបស់គណៈអភិបាល អភិបាលខេត្ត ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រសួងមហាផ្ទៃ ។

**ខ- របៀបរបបការងាររបស់គណៈអភិបាលខេត្ត**

**១-ការប្រគល់សិទ្ធិចុះហត្ថលេខា**

អភិបាលខេត្ត ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន លើកលែងតែលិខិតបទដ្ឋានដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាខេត្តចុះហត្ថលេខា ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

អភិបាលខេត្ត អាចប្រគល់សិទ្ធិជូនអភិបាលរងខេត្តក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន ក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងខេត្តនីមួយៗ។ អភិបាលខេត្ត ត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ និងបែបបទ នីតិវិធីចំពោះឯកសារ លិខិតស្នាម ដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងខេត្ត។ អភិបាលខេត្ត មានសិទ្ធិដកហូតមកវិញ នូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងខេត្តណាមួយ ដែលប្រើប្រាស់អំណាចនេះ មិនស្របច្បាប់ និងមិនស្របតាមបែបបទ នីតិវិធី ។ ការប្រគល់និងការដកហូតសិទ្ធិក្នុងការចុះហត្ថលេខានេះ អភិបាលខេត្ត ត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន ។

**២-ការផ្ទេរសិទ្ធិនៅពេលអភិបាលខេត្ត អវត្តមាន**

ក្នុងករណីអភិបាលខេត្ត អវត្តមានពីដែនសមត្ថកិច្ចរបស់ខ្លួន អភិបាលខេត្តត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងខេត្តមួយរូប ឱ្យទទួលជាអភិបាលខេត្តស្តីទី ដើម្បីធានានិរន្តរភាពរាល់កិច្ចការក្នុងរដ្ឋបាលខេត្ត ។ ជាគោលការណ៍ អភិបាលរងខេត្ត ដែលទទួលបានការផ្ទេរសិទ្ធិពីអភិបាល ពុំមានសិទ្ធិក្នុងការផ្ទេរសិទ្ធិបន្តទៅអភិបាលរងណាមួយបានឡើយ ។

ប្រសិនបើអភិបាលខេត្ត អវត្តមានដោយករណីចៃដន្យណាមួយដែលពុំអាចផ្ទេរសិទ្ធិបាន អភិបាលរងខេត្តដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃអនុក្រឹត្យតែងតាំងអភិបាលរងនៃគណៈអភិបាលខេត្ត ត្រូវធ្វើជាអភិបាលខេត្តស្តីទី ។ ក្នុងករណីអភិបាលរងខេត្ត ដែលមានលំដាប់លេខរៀងលើគេត្រូវបានផ្លាស់ប្តូរចេញ អភិបាលរងខេត្ត ដែលនៅលំដាប់លេខរៀងបន្ទាប់ ត្រូវផ្តល់អាទិភាពសម្រាប់ធ្វើជាអភិបាលស្តីទី ។

ក្នុងករណីអភិបាលខេត្តស្តីទីអវត្តមានដោយគ្មានមូលហេតុ នាយករដ្ឋបាលខេត្ត ត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់មកក្រសួងមហាផ្ទៃ ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាស ដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងខេត្តមួយរូប ឱ្យទទួលជាអភិបាលខេត្តស្តីទី។

អភិបាលខេត្តស្តីទី ត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលខេត្ត នៅពេលដែលអភិបាលខេត្ត មានវត្តមានវិញ។

**៣-ការងាររដ្ឋបាល លិខិតស្នាមរដ្ឋបាល និងការប្រជុំ**

នាយករដ្ឋបាលសាលាខេត្ត មានតួនាទីជាជំនួយការដល់ក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត ក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងការធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងសាលាខេត្ត។ ជាគោលការណ៍ គណៈអភិបាលមិនត្រូវបង្កើតក្រុមជំនួយការ សម្រាប់ជួយការងាររបស់ខ្លួនក្រៅពីរចនាសម្ព័ន្ធរបស់សាលាខេត្តឡើយ។ នាយករដ្ឋបាល

និងរចនាសម្ព័ន្ធចំណុះសាលាខេត្ត មានតួនាទីធ្វើជាសេនាធិការនិងជំនួយការជូនគណៈអភិបាលខេត្ត ក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួន ដូចបានរៀបរាប់ខាងលើ ។

គ្រប់កិច្ចការនានាដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន គណៈអភិបាលខេត្តត្រូវដឹកនាំ ណែនាំនាយករដ្ឋបាលក្នុងការប្រគល់កិច្ចការឱ្យទីចាត់ការ និងការិយាល័យដែលទទួលខុសត្រូវការងារនីមួយៗ ដើម្បីសិក្សា ស្រាវជ្រាវលើកយោបល់ ដោយផ្អែកតាមគោលការណ៍ច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន នីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុរួចបញ្ជូនមកនាយករដ្ឋបាល ដើម្បីបញ្ជូនទៅអភិបាលរងទទួលបន្ទុកលើការងារ ឬវិស័យនីមួយៗ ពិនិត្យ និងផ្តល់យោបល់ មុនដាក់ជូនអភិបាលខេត្ត ពិនិត្យ សម្រេច ស្របតាមបែបបទ នីតិវិធី និងសមត្ថកិច្ចរបស់ខ្លួន។

រាល់លិខិតស្នាម និងលិខិតបទដ្ឋានត្រូវបញ្ជូនតាមច្រកចេញចូលតែមួយ គឺតាមរយៈការិយាល័យរបៀប និងឯកសារ នៃទីចាត់ការរដ្ឋបាលសាលាខេត្ត។ នាយកទីចាត់ការរដ្ឋបាល ត្រូវរាយការណ៍ និង ស្នើសុំយោបល់ពីនាយករដ្ឋបាលសាលាខេត្ត ដើម្បីធ្វើការបែងចែករាល់លិខិតស្នាមជូនដល់ការិយាល័យ និងទីចាត់ការ ជំនាញនានាជាសមត្ថកិច្ច និងមានភារកិច្ចពិនិត្យអំពីទម្រង់រដ្ឋបាលនៃឯកសារនានា មុននឹងបញ្ជូនទៅអភិបាលរងខេត្តទទួលបន្ទុកផ្តល់យោបល់។ បន្ទាប់ពីទទួលបានយោបល់របស់អភិបាលរងខេត្ត ទទួលបន្ទុករួចហើយ នាយករដ្ឋបាលសាលាខេត្តត្រូវដាក់ឯកសារទាំងអស់នោះជូនអភិបាលខេត្ត ឬអភិបាលខេត្តស្តីទី ពិនិត្យ និងសម្រេច។

ចំពោះការងារណាមានលក្ខណៈសំខាន់ចាំបាច់ អភិបាលខេត្ត ឬ អភិបាលខេត្តស្តីទី ត្រូវធ្វើការប្រជុំពិគ្រោះ យោបល់ជាមួយអភិបាលរងខេត្តទាំងអស់ មុននឹងធ្វើសេចក្តីសម្រេចចិត្ត ។

នាយកទីចាត់ការ និងប្រធានការិយាល័យនានា ត្រូវធានាចាត់ចែងមន្ត្រី បុគ្គលិកក្នុងការិយាល័យនីមួយៗ ដើម្បីអនុវត្តការងារ ផ្អែកតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងផ្អែកតាមនីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងល័ក្ខខ័ណ្ឌ ការងារដែលបានកំណត់ ។

ការគ្រប់គ្រង ការបោះត្រា និងការថែរក្សាត្រារដ្ឋបាលខេត្ត ជាសមត្ថកិច្ចទទួលខុសត្រូវរបស់ការិយាល័យរបៀប និងឯកសារ ចំណុះទីចាត់ការរដ្ឋបាលសាលាខេត្ត ។

អភិបាលខេត្ត ត្រូវកំណត់ឱ្យមានការប្រជុំថ្នាក់ដឹកនាំខេត្ត ប្រចាំអឌ្ឍមាស ហើយការប្រជុំអឌ្ឍមាសទី២ នៃខែនីមួយៗ ជាការប្រជុំប្រចាំខែ។

ក្រៅពីការប្រជុំប្រចាំអឌ្ឍមាសនិងការប្រជុំប្រចាំខែខាងលើ គណៈអភិបាលខេត្តអាចកោះប្រជុំ តាមការចាំបាច់ ដើម្បីពិគ្រោះពិភាក្សាលើបញ្ហាណាមួយដែលខ្លួនយល់ឃើញថា ចាំបាច់ត្រូវពិភាក្សាក្នុងគណៈអភិបាលខេត្ត សំដៅលើកកម្ពស់ការចូលរួមអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា។

រៀងរាល់កិច្ចប្រជុំនីមួយៗ ត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ។ រាល់ការប្រជុំប្រចាំខែ អភិបាលខេត្ត ត្រូវធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន ក្នុងរៀងរាល់កិច្ចប្រជុំក្រុមប្រឹក្សា ។

## II-គណៈអភិបាលក្រុង គណៈអភិបាលស្រុក

### ក-ការបែងចែកតួនាទី ភារកិច្ចក្នុងជួរគណៈអភិបាលក្រុង ស្រុក

ផ្អែកតាមរចនាសម្ព័ន្ធថ្មីរបស់សាលាក្រុង ស្រុក គណៈអភិបាលក្រុង ស្រុក ត្រូវប្រជុំពិភាក្សា ដើម្បីបែងចែកភារកិច្ចដល់អភិបាលក្រុង ស្រុក និងអភិបាលរងក្រុង ស្រុក ដើម្បីទទួលខុសត្រូវជួយទៅលើការងារនៅតាមការិយាល័យ និងកិច្ចការនៃវិស័យនានាដែលពាក់ព័ន្ធ ហើយសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន ។

អភិបាលក្រុង ស្រុក ត្រូវធ្វើការបែងចែកភារកិច្ចដល់អភិបាលរងក្រុង ស្រុក ក្នុងគណៈអភិបាលរបស់ខ្លួន ឱ្យជួយក្នុងការងារនៅក្នុងរដ្ឋបាលក្រុង ស្រុក ។ អភិបាលរងនីមួយៗ ដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលក្រុង ស្រុក លើភារកិច្ចនានាដែលបានប្រគល់ ហើយត្រូវរួមជាមួយអភិបាលក្រុង ស្រុក ដើម្បីទទួលខុសត្រូវអំពីការសម្រេចនិងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន ។

**ការបែងចែកភារកិច្ចខាងលើ អាចត្រូវបានអនុវត្តដូចខាងក្រោម :**

**១-ការបែងចែកភារកិច្ចសម្រាប់ក្រុង ស្រុក ដែលមានគណៈអភិបាលចំនួន ០៣រូប :**

**១-១ សម្រាប់ក្រុងមានគណៈអភិបាល ០៣រូប**

- **អភិបាលក្រុង** ទទួលបន្ទុកដឹកនាំការងាររួម និងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការងារនៅការិយាល័យផែនការនិងគាំទ្រសង្កាត់ កិច្ចការផែនការ កិច្ចការវិនិយោគ កិច្ចការអភិវឌ្ឍន៍ជនបទ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន កិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ និងជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលក្រុង លើការងារការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ និងទទួលជួយកិច្ចការនារីនិងកុមារ អប់រំ យុវជន និងកីឡា កិច្ចការទេសចរណ៍ វប្បធម៌ ធម្មការនិងសាសនា សុខាភិបាល កិច្ចការស្ថិតិ និងអត្រានុកូលដ្ឋាន កិច្ចការព័ត៌មាន ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កិច្ចការធនាគារ រតនាគារ ពន្ធដារ សាខាកាំកុងត្រូល គយនិងរដ្ឋាករ និងកិច្ចការលទ្ធកម្ម ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលក្រុង លើការងារការិយាល័យអភិវឌ្ឍក្រុង និងទទួលជួយកិច្ចការសាធារណការនិងដឹកជញ្ជូន កិច្ចការបរិស្ថាន កិច្ចការគ្រប់គ្រងកាកសំណល់រឹងនិងរាវ កិច្ចការនគរូបនីយកម្ម សំណង់និងសុរិយោដី កិច្ចការសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល សមាគម គណបក្សនយោបាយ កិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ កិច្ចការសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កិច្ចការកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល កិច្ចការពាណិជ្ជកម្ម កិច្ចការឧស្សាហកម្ម រ៉ែនិងថាមពល ទឹកស្អាត កិច្ចការធនធានទឹក ឧតុនិយម និងធារាសាស្ត្រ កិច្ចការប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**១-២ សម្រាប់ស្រុកមានគណៈអភិបាល ០៣រូប**

- **អភិបាលស្រុក** ទទួលបន្ទុកដឹកនាំការងាររួម និងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការងារនៅការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ កិច្ចការផែនការ កិច្ចការវិនិយោគ កិច្ចការអភិវឌ្ឍន៍ជនបទ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន កិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ និងជាអាណាប័ក ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលស្រុក លើការងារការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ និងទទួលជួយកិច្ចការនារីនិងកុមារ អប់រំ យុវជន និងកីឡា កិច្ចការទេសចរណ៍ វប្បធម៌ ធម្មការនិងសាសនា សុខាភិបាល កិច្ចការស្ថិតិ និងអត្រានុកូលដ្ឋាន កិច្ចការព័ត៌មាន ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កិច្ចការធនាគារ រតនាគារ ពន្ធដារ សាខាកាំកុងត្រូល គយនិងរដ្ឋាករ និងកិច្ចការលទ្ធកម្ម ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលស្រុក លើការងារការិយាល័យអន្តរវិស័យ និងទទួលជួយកិច្ចការសាធារណការនិងដឹកជញ្ជូន កិច្ចការបរិស្ថាន កិច្ចការគ្រប់គ្រងកាកសំណល់រឹងនិងរាវ កិច្ចការនគរូបនីយកម្ម សំណង់ និងសុរិយោដី កិច្ចការសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល សមាគម គណបក្សនយោបាយ កិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ កិច្ចការសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កិច្ចការកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល កិច្ចការពាណិជ្ជកម្ម កិច្ចការឧស្សាហកម្ម រ៉ែនិងថាមពល ទឹកស្អាត កិច្ចការធនធានទឹក ឧតុនិយម និងធារាសាស្ត្រ កិច្ចការប្រៃសណីយ៍និងទូរគមនាគមន៍ ។

**២-ការបែងចែកភារកិច្ចសម្រាប់ក្រុង ស្រុក ដែលមានគណៈអភិបាលចំនួន ០៤រូប :**

**២-១ សម្រាប់ក្រុងមានគណៈអភិបាល ០៤រូប**

- **អភិបាលក្រុង** ទទួលបន្ទុកដឹកនាំការងាររួម និងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលក្រុង លើកិច្ចការនារីនិងកុមារ កិច្ចការសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល សមាគម គណបក្សនយោបាយ កិច្ចការស្ថិតិ និងអត្រានុកូលដ្ឋាន កិច្ចការព័ត៌មាន ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កិច្ចការធនាគារ រតនាគារ ពន្ធដារ សាខាកាំកុងត្រូល គយ និងរដ្ឋាករ និងកិច្ចការលទ្ធកម្ម ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលក្រុង លើការងារកិច្ចការផែនការ និងគាំទ្រសង្កាត់ កិច្ចការវិនិយោគ កិច្ចការអភិវឌ្ឍន៍ជនបទ កិច្ចការអប់រំ យុវជន និងកីឡា ទេសចរណ៍ វប្បធម៌ សាសនា សុខាភិបាល កិច្ចការសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង កិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលក្រុង លើកិច្ចការសាធារណការ និង ដឹកជញ្ជូន កិច្ចការបរិស្ថាន កិច្ចការគ្រប់គ្រងកាកសំណល់រឹងនិងរាវ កិច្ចការនគរូបនីយកម្ម សំណង់ និងសុរិយោដី កិច្ចការសម្របសម្រួលទំនាស់

ក្រៅប្រព័ន្ធតុលាការ កិច្ចការកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល កិច្ចការពាណិជ្ជកម្ម កិច្ចការឧស្សាហកម្ម រ៉ែនិងថាមពល ទឹកស្អាត កិច្ចការធនធានទឹក ឧតុនិយមនិងធារាសាស្ត្រ កិច្ចការប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**២-២ សម្រាប់ស្រុកមានគណៈអភិបាល ០៤រូប**

- **អភិបាលស្រុក** ទទួលបន្ទុកដឹកនាំការងាររួម និងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលស្រុក លើកិច្ចការនារីនិងកុមារ កិច្ចការសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល សមាគម គណបក្សនយោបាយ កិច្ចការស្ថិតិ និងអត្រានុកូលដ្ឋាន កិច្ចការព័ត៌មាន ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កិច្ចការធនាគារ ពន្ធដារ សាខាកាំកុងត្រូល គយនិងរដ្ឋាករ និងកិច្ចការលទ្ធកម្ម ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលស្រុក លើកិច្ចការផែនការ និងគាំទ្រឃុំ សង្កាត់ កិច្ចការវិនិយោគ កិច្ចការអភិវឌ្ឍន៍ជនបទ កិច្ចការអប់រំ យុវជននិងកីឡា ទេសចរណ៍ ធម្មការនិងសាសនា សុខាភិបាល វប្បធម៌ កិច្ចការសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និងកិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលស្រុក លើកិច្ចការសាធារណការនិងដឹកជញ្ជូន កិច្ចការបរិស្ថាន កិច្ចការនគរូបនីយកម្ម សំណង់ និងសុរិយោដី កិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ កិច្ចការកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និង រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល កិច្ចការពាណិជ្ជកម្ម កិច្ចការឧស្សាហកម្ម រ៉ែ និង ថាមពល ទឹកស្អាត កិច្ចការធនធានទឹក ឧតុនិយមនិងធារាសាស្ត្រ និងកិច្ចការប្រៃសណីយ៍និងទូរគមនាគមន៍ ។

**៣-ការបែងចែកភារកិច្ចសម្រាប់ក្រុង ស្រុក ដែលមានគណៈអភិបាលចំនួន ០៥រូប :**

**៣-១ សម្រាប់ក្រុងមានគណៈអភិបាល ០៥រូប**

- **អភិបាលក្រុង** ទទួលបន្ទុកដឹកនាំការងាររួម និងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលក្រុង លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កិច្ចការសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កិច្ចការធនាគារ រតនាគារ ពន្ធដារ សាខាកាំកុងត្រូល គយនិងរដ្ឋាករ និង កិច្ចការលទ្ធកម្ម ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលក្រុង លើកិច្ចការនារីនិងកុមារ កិច្ចការព័ត៌មាន ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការអប់រំ យុវជន និងកីឡា កិច្ចការស្ថិតិ និងអត្រានុកូលដ្ឋាន និងកិច្ចការសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល សមាគម គណបក្សនយោបាយ ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលក្រុង លើកិច្ចការផែនការ និងគាំទ្រសង្កាត់ កិច្ចការវិនិយោគ កិច្ចការអភិវឌ្ឍន៍ជនបទ កិច្ចការទេសចរណ៍ វប្បធម៌ សាសនា សុខាភិបាល និងកិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលក្រុង លើកិច្ចការសាធារណការ និងដឹកជញ្ជូន កិច្ចការបរិស្ថាន កិច្ចការគ្រប់គ្រងកាកសំណល់រឹងនិងរាវ កិច្ចការនគរូបនីយកម្ម សំណង់និងសុរិយោដី កិច្ចការកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល កិច្ចការពាណិជ្ជកម្ម កិច្ចការឧស្សាហកម្ម រ៉ែ និងថាមពល ទឹកស្អាត កិច្ចការធនធានទឹក ឧតុនិយម និងធារាសាស្ត្រ កិច្ចការប្រៃសណីយ៍ និងទូរគមនាគមន៍ និងកិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ ។

**៣-២ សម្រាប់ស្រុកមានគណៈអភិបាល ០៥រូប**

- **អភិបាលស្រុក** ទទួលបន្ទុកដឹកនាំការងាររួម និងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលស្រុក លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កិច្ចការសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កិច្ចការធនាគារ រតនាគារ ពន្ធដារ សាខាកាំកុងត្រូល គយនិងរដ្ឋាករ និងកិច្ចការលទ្ធកម្ម។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលស្រុក លើកិច្ចការនារី និងកុមារ កិច្ចការព័ត៌មាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការអប់រំ យុវជន និងកីឡា កិច្ចការស្ថិតិ និងអត្រានុកូលដ្ឋាន និងកិច្ចការ សិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល សមាគម គណបក្សនយោបាយ ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលក្រុង លើកិច្ចការផែនការនិងគាំទ្រឃុំសង្កាត់ កិច្ចការវិនិយោគ កិច្ចការអភិវឌ្ឍន៍ជនបទ កិច្ចការទេសចរណ៍ វប្បធម៌ ធម្មការនិងសាសនា សុខាភិបាល និងកិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ ។

- **អភិបាលរងមួយរូប** ទទួលជួយអភិបាលស្រុក លើកិច្ចការសាធារណការ និងដឹកជញ្ជូន កិច្ចការបរិស្ថាន កិច្ចការគ្រប់គ្រងកាកសំណល់រឹងនិងរាវ កិច្ចការនគរូបនីយកម្ម សំណង់ និង សុរិយោដី កិច្ចការកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល កិច្ចការពាណិជ្ជកម្ម កិច្ចការឧស្សាហកម្ម រ៉ែនិងថាមពល ទឹកស្អាត កិច្ចការធនធានទឹក ឧតុនិយម និងធារាសាស្ត្រ កិច្ចការប្រៃសណីយ៍ និងទូរគមនាគមន៍ និងកិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ ។

ផ្អែកតាមការបែងចែកតួនាទី ភារកិច្ចខាងលើ អភិបាលក្រុង ស្រុក ត្រូវពិភាក្សាដើម្បីចាត់អភិបាលរងក្រុង ស្រុក ទៅក្នុងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខ្លួន ឱ្យបានសមស្របតាមសមត្ថភាព បទពិសោធន៍ជំនាញ និងការបែងចែកភារកិច្ច ដូចបានកំណត់ខាងលើផងដែរ ។

ក្រៅពីភារកិច្ចដែលបានបែងចែកដល់អភិបាលរងក្រុង ស្រុក អភិបាលអាចប្រគល់ភារកិច្ចបន្ថែមជូនអភិបាលរង ទៅតាមសំណូមពរការងារជាក់ស្តែងរបស់រដ្ឋបាលក្រុង ស្រុកនីមួយៗ ។

ក្នុងករណីដែលមានការផ្លាស់ប្តូរអភិបាលឬអភិបាលរងក្រុង ស្រុក អភិបាលឬអភិបាលរងក្រុង ស្រុក ចូលកាន់តំណែង ត្រូវបន្តអនុវត្តភារកិច្ចពីអភិបាលឬអភិបាលរងក្រុង ស្រុក ដែលត្រូវបានផ្លាស់ចេញ ឬទទួលភារកិច្ច តាមការពិភាក្សាបែងចែករបស់គណៈអភិបាល បន្ទាប់ពីមានការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន ។

បន្ទាប់ពីបានពិនិត្យ ពិភាក្សាក្នុងគណៈអភិបាលរួចហើយ អភិបាលក្រុង ស្រុកត្រូវរៀបចំសេចក្តីព្រាង **សេចក្តីសម្រេច**ស្តីពីការបែងចែកតួនាទី ភារកិច្ចនិងរបៀបរបបការងារជូនគណៈអភិបាលក្រុង គណៈអភិបាលស្រុក ដើម្បីស្នើសុំការពិនិត្យ សម្រេចពីក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ។ ផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សារបស់ខ្លួន អភិបាលក្រុង ស្រុក ត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបការងារជូនគណៈអភិបាលក្រុង គណៈអភិបាលស្រុក ( **ដូចមានគំរូជូនភ្ជាប់** ) ។

ក្នុងករណីក្រុមប្រឹក្សាមិនឯកភាពទៅលើសេចក្តីព្រាងសេចក្តីសម្រេចដែលស្នើឡើង គណៈអភិបាលត្រូវយកមតិយោបល់របស់ក្រុមប្រឹក្សាមកពិនិត្យ ពិចារណា ដើម្បីកែសម្រួលតាមសេចក្តីព្រាងសេចក្តីសម្រេចនោះ ឱ្យបានស្របទៅតាមស្មារតីប្រជុំក្រុមប្រឹក្សា។ ប៉ុន្តែប្រសិនបើ គណៈអភិបាលពុំអាចកែសម្រួលបានទេ អភិបាលក្រុង ស្រុក ត្រូវរាយការណ៍បំភ្លឺជូនក្រុមប្រឹក្សារបស់ខ្លួន អំពីមូលហេតុដែលពុំអាចធ្វើការកែសម្រួលបាន ដើម្បីស្នើសុំការសម្រេចពីក្រុមប្រឹក្សាជាថ្មីម្តងទៀត។

សេចក្តីសម្រេចរបស់អភិបាលក្រុង ស្រុក ត្រូវបញ្ជូនមកសាលាខេត្ត ដើម្បីដាក់ជូនអភិបាលខេត្ត ពិនិត្យសម្រេចផ្តល់អនុលោមភាព ។ ករណីអភិបាលខេត្ត ពិនិត្យឃើញថា សេចក្តីសម្រេចរបស់អភិបាលក្រុង ស្រុក មិនមានលក្ខណៈសមស្របឬមិនមានមូលដ្ឋានគតិយុត្តត្រឹមត្រូវ អភិបាលខេត្តអាចបញ្ជូនសេចក្តីសម្រេចនោះ ទៅរដ្ឋបាលក្រុង ស្រុក ដោយភ្ជាប់ជាមួយនូវមតិយោបល់ និងអនុសាសន៍ជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យក្រុង ស្រុក ធ្វើការកែសម្រួលសេចក្តីសម្រេចនោះឡើងវិញ ។ អភិបាលក្រុង ស្រុក ត្រូវធ្វើការកែសម្រួលសេចក្តីសម្រេចរបស់ខ្លួន និងត្រូវចុះហត្ថលេខារួចបញ្ជូនមកអភិបាលខេត្ត ដើម្បីផ្តល់អនុលោមភាពជាថ្មី ។ អភិបាលក្រុង ស្រុក ត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន អំពីការកែសម្រួលនេះ ។

នៅពេលមានការបំពេញបន្ថែម ឬកែសម្រួលភារកិច្ចរបស់អភិបាលរងណាមួយ ឬរបស់គណៈអភិបាល អភិបាលក្រុង ស្រុក ត្រូវធ្វើសេចក្តីរាយការណ៍ជូនអភិបាលខេត្ត ។

## ខ-របៀបរបបការងាររបស់គណៈអភិបាលក្រុង គណៈអភិបាលស្រុក

### ១-ការប្រគល់សិទ្ធិចុះហត្ថលេខា

អភិបាលក្រុង ស្រុក ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន លើកលែងតែលិខិតបទដ្ឋានដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សា ក្រុង ស្រុក ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

អភិបាលក្រុង ស្រុក អាចប្រគល់សិទ្ធិដល់អភិបាលរងក្រុង ស្រុក ក្នុងការចុះហត្ថលេខាលើឯកសារលិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន ក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងក្រុង ស្រុកនីមួយៗ។ អភិបាលក្រុង ស្រុក ត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ និងបែបបទ នីតិវិធីចំពោះឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងក្រុង ស្រុក ។ អភិបាលក្រុង ស្រុក មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងណាមួយដែលប្រើប្រាស់អំណាចនេះ មិនស្របច្បាប់ និងមិនស្របតាមបែបបទនីតិវិធី ។ ការប្រគល់និងការដកហូតសិទ្ធិក្នុងការចុះហត្ថលេខានេះ អភិបាលក្រុង ស្រុក ត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន ។

**២-ការផ្ទេរសិទ្ធិនៅពេលអភិបាលក្រុង អភិបាលស្រុក អវត្តមាន**

ក្នុងករណីអភិបាលក្រុង ស្រុក អវត្តមានពីដែនសមត្ថកិច្ចរបស់ខ្លួន អភិបាលក្រុង ស្រុក ត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងក្រុង ស្រុកមួយរូប ឱ្យទទួលជាអភិបាលក្រុង ស្រុកស្ដីទី ដើម្បីធានានិរន្តរភាពរាល់កិច្ចការក្នុងរដ្ឋបាលក្រុង ស្រុក ។ ជាគោលការណ៍ អភិបាលរងក្រុង ស្រុក ដែលទទួលបានការផ្ទេរសិទ្ធិពីអភិបាល ពុំមានសិទ្ធិក្នុងការផ្ទេរសិទ្ធិបន្តទៅអភិបាលរងណាមួយបានឡើយ ។

ប្រសិនបើអភិបាលក្រុង ស្រុក អវត្តមានដោយករណីចៃដន្យណាមួយដែលពុំអាចផ្ទេរសិទ្ធិបាន អភិបាលរងក្រុង ស្រុក ដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃប្រកាសតែងតាំងអភិបាលរងនៃគណៈអភិបាលក្រុង ស្រុក ត្រូវធ្វើជាអភិបាលក្រុង ស្រុកស្ដីទី។ ក្នុងករណីអភិបាលរងក្រុង ស្រុក ដែលមានលំដាប់លេខរៀងលើគេ ត្រូវបានផ្លាស់ប្ដូរចេញ អភិបាលរងដែលនៅលំដាប់លេខរៀងបន្ទាប់ ត្រូវផ្ដល់អាទិភាពសម្រាប់ធ្វើជាអភិបាលស្ដីទី ។

ក្នុងករណីអភិបាលក្រុង ស្រុកស្ដីទីអវត្តមាន ដោយគ្មានមូលហេតុ នាយករដ្ឋបាលសាលាក្រុង ស្រុក ត្រូវធ្វើសេចក្ដីរាយការណ៍ជាបន្ទាន់ជូនរដ្ឋបាលខេត្ត ។ អភិបាលខេត្តត្រូវចេញ**ដីកា** ដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងក្រុង ស្រុកមួយរូប ឱ្យទទួលជាអភិបាលក្រុង ស្រុកស្ដីទី និងត្រូវធ្វើសេចក្ដីរាយការណ៍ជូនក្រុមប្រឹក្សាខេត្ត ។ ដីការបស់អភិបាលខេត្ត ត្រូវចម្លងជូនក្រសួងមហាផ្ទៃ។

អភិបាលក្រុង ស្រុកស្ដីទី ត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលក្រុង ស្រុក នៅពេលដែលអភិបាលក្រុង ស្រុក មានវត្តមានវិញ។

**៣-ការងាររដ្ឋបាល លិខិតស្នាមរដ្ឋបាល និងការប្រជុំ**

នាយករដ្ឋបាលសាលាក្រុង ស្រុក មានតួនាទីជាជំនួយការដល់ក្រុមប្រឹក្សានិងគណៈអភិបាលក្រុង ស្រុក ក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងការធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងសាលាក្រុង ស្រុក ។ ជាគោលការណ៍ គណៈអភិបាលមិនត្រូវបង្កើតក្រុមជំនួយការសម្រាប់ជួយការងាររបស់ខ្លួនក្រៅពីរចនាសម្ព័ន្ធរបស់សាលាក្រុង ស្រុក ឡើយ។ នាយករដ្ឋបាលនិងរចនាសម្ព័ន្ធចំណុះសាលាក្រុង ស្រុក មានតួនាទីធ្វើជាសេនាធិការនិងជំនួយការជូនគណៈអភិបាលក្រុង ស្រុក ក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួនដូចបានរៀបរាប់ខាងលើ ។

គ្រប់កិច្ចការនានាដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន គណៈអភិបាលក្រុង ស្រុក ត្រូវដឹកនាំ ណែនាំ នាយករដ្ឋបាលក្នុងការប្រគល់កិច្ចការឱ្យការិយាល័យ ដែលទទួលខុសត្រូវការងារនីមួយៗ ដើម្បីសិក្សា ស្រាវជ្រាវ លើកយោបល់ ដោយផ្អែកតាមគោលការណ៍ច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន នីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ រួចបញ្ជូនមកនាយករដ្ឋបាល ដើម្បីបញ្ជូនទៅអភិបាលរងទទួលបន្ទុកលើការងារ ឬវិស័យនីមួយៗ ពិនិត្យ និង ផ្តល់យោបល់ មុនដាក់ជូនអភិបាលក្រុង ស្រុក ពិនិត្យ សម្រេច ស្របតាមបែបបទ នីតិវិធី និងសមត្ថកិច្ចរបស់ខ្លួន។

រាល់លិខិតស្នាម និងលិខិតបទដ្ឋានត្រូវបញ្ជូនតាមច្រកចេញចូលតែមួយគឺតាមរយៈការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុសាលាក្រុង ស្រុក ។ ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ត្រូវរាយការណ៍ និងស្នើសុំយោបល់ពី នាយករដ្ឋបាលសាលាក្រុង ស្រុក ដើម្បីធ្វើការបែងចែករាល់លិខិតស្នាមជូនដល់ការិយាល័យជំនាញនានា ជាសមត្ថកិច្ច និងមានភារកិច្ចពិនិត្យអំពីទម្រង់រដ្ឋបាលនៃឯកសារនានា មុននឹងបញ្ជូនទៅអភិបាលរងក្រុង ស្រុក ទទួលបន្ទុកផ្តល់ យោបល់ ។ បន្ទាប់ពីទទួលបានយោបល់របស់អភិបាលរងក្រុង ស្រុក ទទួលបន្ទុករួចហើយ នាយករដ្ឋបាល សាលាក្រុង ស្រុក ត្រូវដាក់ឯកសារទាំងអស់នោះ ជូនអភិបាលក្រុង ស្រុក ឬអភិបាលស្តីទី ពិនិត្យ និង សម្រេច។

ចំពោះការងារណាមានលក្ខណៈសំខាន់ចាំបាច់ អភិបាលក្រុង ស្រុក ឬអភិបាលស្តីទី ត្រូវធ្វើការប្រជុំ ពិគ្រោះ យោបល់ជាមួយអភិបាលរងក្រុង ស្រុកទាំងអស់ មុននឹងធ្វើសេចក្តីសម្រេចចិត្ត ។

ប្រធានការិយាល័យនានា ត្រូវធានាចាត់ចែងមន្ត្រី បុគ្គលិកក្នុងការិយាល័យនីមួយៗ ដើម្បីអនុវត្តការងារ ផ្អែកតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងផ្អែកតាមនីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងល័ក្ខខ័ណ្ឌការងារ ដែលបានកំណត់ ។

ការគ្រប់គ្រង ការបោះត្រា និងការថែរក្សាត្រារដ្ឋបាលក្រុង ស្រុក ជាសមត្ថកិច្ចទទួលខុសត្រូវរបស់ ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុសាលាក្រុង ស្រុក ។

អភិបាលក្រុង ស្រុក ត្រូវកំណត់ឱ្យមានការប្រជុំថ្នាក់ដឹកនាំក្រុង ស្រុក ប្រចាំអឌ្ឍមាស ហើយការប្រជុំ អឌ្ឍមាសទី២នៃខែនីមួយៗ ជាការប្រជុំប្រចាំខែ។

ក្រៅពីការប្រជុំប្រចាំអឌ្ឍមាសនិងការប្រជុំប្រចាំខែខាងលើ គណៈអភិបាលក្រុង ស្រុក អាចកោះប្រជុំ តាមការចាំបាច់ ដើម្បីពិគ្រោះពិភាក្សាលើបញ្ហាណាមួយ ដែលខ្លួនយល់ឃើញថា ចាំបាច់ត្រូវធ្វើការពិភាក្សាក្នុង គណៈអភិបាលក្រុង ស្រុក សំដៅលើកកម្ពស់ការចូលរួមអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន នានា។

របៀបវារៈកិច្ចប្រជុំនីមួយៗ ត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ។ រាល់ការប្រជុំប្រចាំខែ អភិបាលក្រុង ស្រុក ត្រូវធ្វើរបាយការណ៍ជូនអភិបាលខេត្ត និង ត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន ក្នុងរបៀបវារៈកិច្ចប្រជុំ ក្រុមប្រឹក្សា ។៚

ក្នុងការអនុវត្តសេចក្តីណែនាំនេះ ករណីជួបប្រទះការលំបាកដែលមិនអាចដោះស្រាយបាន គណៈអភិបាលខេត្ត ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សារបស់ខ្លួន រួចលើកសំណើមកក្រសួងមហាផ្ទៃ ដើម្បីពិនិត្យនិងកែសម្រួលតាមការចាំបាច់ ។

ចំពោះក្រុង ស្រុកនានា គណៈអភិបាលខេត្តត្រូវជួយសម្របសម្រួលក្នុងការអនុវត្តសេចក្តីណែនាំនេះ និងត្រូវធ្វើសំណើមកក្រសួងមហាផ្ទៃ ករណីមិនអាចសម្របសម្រួលបាន។ ទន្ទឹមនេះ ក្រសួងមហាផ្ទៃនឹងធ្វើការពិនិត្យវាយតម្លៃឡើងវិញ អំពីប្រសិទ្ធភាពនៃការអនុវត្តសេចក្តីណែនាំនេះ ដើម្បីធ្វើការកែសម្រួលតាមការចាំបាច់ ។

ទទួលបានសេចក្តីណែនាំនេះ ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក និង អង្គភាពដែលពាក់ព័ន្ធ ត្រូវចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។៕

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ៥ ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**<u>ចម្លងជូន</u> :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- លេខាធិការដ្ឋាន គ.ជ.អ.ប

*( ដើម្បីជូនជ្រាប)*

- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខេត្ត....................

លេខ..............................

គំរូសម្រាប់ខេត្ត

# សេចក្តីសម្រេច

## ស្តីពី

## ការបែងចែកតួនាទី ភារកិច្ច និង របៀបរបបធ្វើការងារ

## ជូនគណៈអភិបាលខេត្ត..................................

*******

## អភិបាលខេត្ត....................

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញប្រកាសលេខ ៤២៧៤ ប្រ ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ
- យោងសេចក្តីណែនាំលេខ................ ចុះថ្ងៃទី .......ខែ ...............ឆ្នាំ ២០១០ របស់ក្រសួងមហាផ្ទៃ ស្តីពីការបែងចែកតួនាទី ភារកិច្ចនិងរបៀបរបបធ្វើការងារជូនគណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក
- យោងស្មារតីប្រជុំក្រុមប្រឹក្សាខេត្ត...........ចុះថ្ងៃទី............ខែ ..............ឆ្នាំ២០១០

# ស ម្រេ ច

**ប្រការ១..**

គណៈអភិបាលខេត្ត............. ត្រូវគ្រប់គ្រង និងដឹកនាំដោយអភិបាលខេត្ត ០១រូប និង អភិបាលរង ចំនួន.........រូប ជាជំនួយការ ។

**ប្រការ២..**

អភិបាល និងអភិបាលរងខេត្ត ត្រូវរួមគ្នាដឹកនាំ គ្រប់គ្រងកិច្ចការរដ្ឋបាលដែនដី ការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម និង លើកកំពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ នៅក្នុងក្របខ័ណ្ឌ នៃភូមិសាស្ត្រខេត្ត ស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានដែលនៅមានតំលៃជាធរមាន និង សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ។

**ប្រការ៣..**

អភិបាល និង អភិបាលរងខេត្ត ត្រូវបំពេញមុខងារ និងទទួលខុសត្រូវ ស្របទៅតាមលំដាប់ឋានានុក្រម និង អនុវត្តតួនាទី ភារកិច្ច ដែលបានបែងចែក ដូចមានក្នុងប្រការ ០៤ ។

អភិបាលរងខេត្ត ដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលខេត្ត លើភារកិច្ចនានាដែលបានប្រគល់ ហើយត្រូវរួមជាមួយអភិបាលខេត្ត ទទួលខុសត្រូវអំពីការសម្រេច និងសកម្មភាពក្នុង គណៈអភិបាលរបស់ខ្លួន ។

**ប្រការ៤..**

អភិបាល និង អភិបាលរងខេត្ត............... ត្រូវបានកំណត់នូវការបែងចែកតួនាទី ភារកិច្ចដូចខាងក្រោម ÷

**ក-ការបែងចែកភារកិច្ចសម្រាប់ខេត្តដែលមានគណៈអភិបាលចំនួន ០៥រូប :**

១- **ឯកឧត្តម .............** **អភិបាលខេត្ត.............** ទទួលបន្ទុកដឹកនាំការងាររួម និង ដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ កិច្ចការការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការមុខងារសាធារណៈ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

២- **លោក/លោកស្រី......** **អភិបាលរងខេត្ត** ទទួលជួយអភិបាលខេត្ត លើកិច្ចការព័ត៌មាន កិច្ចការវេទិការសាធារណៈ កិច្ចការស្ថិតិនិងអគ្រានុកូលដ្ឋានខេត្ត កិច្ចការនារីនិងកុមារ អប់រំ យុវជន និងកីឡា វប្បធម៌ ធម្មការនិងសាសនា កិច្ចការទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល គណបក្សនយោបាយ សមាគម និងកិច្ចការសិទ្ធិមនុស្ស កិច្ចការតុលាការនិងពន្ធនាគារ ។

៣. **លោក/លោកស្រី......** **អភិបាលរងខេត្ត** ទទួលជួយអភិបាលខេត្ត លើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កិច្ចការធនាគារ រតនាគារ ពន្ធដារ គយនិងរដ្ឋាករ កិច្ចការសាខាកាំកុងត្រូល និង កិច្ចការលទ្ធកម្មសាធារណៈ ។

៤. **លោក/លោកស្រី......** **អភិបាលរងខេត្ត** ទទួលជួយអភិបាលខេត្ត លើកិច្ចការសាធារណការនិងដឹកជញ្ជូន កិច្ចការនគរូបនីយកម្ម សំណង់ និងសុរិយោដី កិច្ចការទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច កិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ កិច្ចការកសិកម្ម ពាណិជ្ជកម្មឧស្សាហកម្ម ទីកស្អាតនិងអង្គភាពអគ្គិសនី ធនធានទឹក ឧតុនិយមនិងធារាសាស្ត្រ និងកិច្ចការប្រៃសណីយ៍និងទូរគមនាគមន៍ ។

៥. **លោក/លោកស្រី......** **អភិបាលរងខេត្ត** ទទួលជួយអភិបាលខេត្ត លើកិច្ចការវិនិយោគ កិច្ចការផែនការ អភិវឌ្ឍន៍ជនបទ កិច្ចការទេសចរណ៍ កិច្ចការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ សុខាភិបាល កិច្ចការបរិស្ថាន គ្រប់គ្រងកាកសំណល់រឹងនិងរាវ កិច្ចការសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងកិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ និងកិច្ចការព្រំដែន ( ចំពោះខេត្តជាប់ព្រំដែន ) ។

ក្រៅពីភារកិច្ចដែលបានបែងចែកខាងលើ អភិបាលខេត្តអាចប្រគល់ភារកិច្ចបន្ថែមជូនអភិបាលរងខេត្ត ទៅតាមសំណូមពរការងារជាក់ស្តែងរបស់រដ្ឋបាលខេត្ត ។

**ខ. ការបែងចែកភារកិច្ចសម្រាប់ខេត្តដែលមានគណៈអភិបាលចំនួន ០៦រូប :**

១. **ឯកឧត្តម ............** **អភិបាលខេត្ត............** ទទួលបន្ទុកដឹកនាំការងាររួម និងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

២. **លោក/លោកស្រី......** **អភិបាលរងខេត្ត** ទទួលជួយអភិបាលខេត្ត កិច្ចការព័ត៌មាន កិច្ចការនារីនិងកុមារ កិច្ចការវប្បធម៌ ធម្មការនិងសាសនា កិច្ចការវេទិកាសាធារណៈ កិច្ចការស្ថិតិ និងអត្រានុកូលដ្ឋានខេត្ត កិច្ចការទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ កិច្ចការទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច កិច្ចការទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល កិច្ចការគណបក្សនយោបាយ សមាគម និងសិទ្ធិមនុស្ស។

៣. **លោក/លោកស្រី......** **អភិបាលរងខេត្ត** ទទួលជួយអភិបាលខេត្ត លើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កិច្ចការធនាគារ រតនាគារ ពន្ធដារ គយ និងរដ្ឋាករ កិច្ចការសាខាកាំកុងត្រូល និងកិច្ចការលទ្ធកម្មសាធារណៈ ។

៤. **លោក/លោកស្រី......** **អភិបាលរងខេត្ត** ទទួលជួយអភិបាលខេត្ត លើកិច្ចការសាធារណការនិងដឹកជញ្ជូន កិច្ចការនគរូបនីយកម្ម សំណង់ និងសុរិយោដី កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម កិច្ចការទឹកស្អាតនិងអង្គភាពអគ្គិសនី កិច្ចការធនធានទឹក ឧតុនិយមនិងធារាសាស្ត្រ កិច្ចការប្រៃសណីយ៍ និងទូរគមនាគមន៍ ។

៥. **លោក/លោកស្រី......** **អភិបាលរងខេត្ត** ទទួលជួយអភិបាលខេត្ត លើកិច្ចការវិនិយោគ កិច្ចការផែនការ អភិវឌ្ឍន៍ជនបទ កិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ កិច្ចការទេសចរណ៍សុខាភិបាល កិច្ចការបរិស្ថាន គ្រប់គ្រងកាកសំណល់រឹងនិងរាវ និងកិច្ចការសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងកិច្ចការព្រំដែន ( ចំពោះខេត្តជាប់ព្រំដែន ) ។

៦. **លោក/លោកស្រី......** **អភិបាលរងខេត្ត** ទទួលជួយអភិបាលខេត្ត លើកិច្ចការគ្រប់គ្រងធនធានមនុស្ស វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការមុខងារសាធារណៈ កិច្ចការអប់រំ យុវជន និងកីឡា កិច្ចការតុលាការនិងពន្ធនាគារ កិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ ។

ក្រៅពីភារកិច្ចដែលបានបែងចែកខាងលើ អភិបាលខេត្តអាចប្រគល់ភារកិច្ចបន្ថែមជូនអភិបាលរងខេត្ត ទៅតាមសំណូមពរការងារជាក់ស្តែងរបស់រដ្ឋបាលខេត្ត ។

**គ. ការបែងចែកភារកិច្ចសម្រាប់ខេត្តដែលមានគណៈអភិបាលចំនួន ០៧រូប :**

១. **ឯកឧត្តម ............** **អភិបាលខេត្ត............** ទទួលបន្ទុកដឹកនាំការងាររួម និង ដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

២. **លោក/លោកស្រី......** **អភិបាលរងខេត្ត** ទទួលជួយអភិបាលខេត្តលើកិច្ចការព័ត៌មាន លើកិច្ចការនារីនិងកុមារ វប្បធម៌ ធម្មការនិងសាសនា កិច្ចការទេសចរណ៍ ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ ។

៣. **លោក/លោកស្រី......** **អភិបាលរងខេត្ត** ទទួលជួយអភិបាលខេត្តលើកិច្ចការស្ថិតិនិងអត្រានុកូលដ្ឋានខេត្ត កិច្ចការវេទិការសាធារណៈ កិច្ចការតុលាការនិងពន្ធនាគារ និងកិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ កិច្ចការទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច កិច្ចការទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល គណបក្សនយោបាយ សមាគម និងកិច្ចការសិទ្ធិមនុស្ស។

៤. **លោក/លោកស្រី......** **អភិបាលរងខេត្ត** ទទួលជួយអភិបាលខេត្ត ទៅលើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កិច្ចការធនាគារ រតនាគារ ពន្ធដារ គយ និងរដ្ឋាករ កិច្ចការសាខាកាំកុងត្រូល និងកិច្ចការលទ្ធកម្មសាធារណៈ ។

៥. **លោក/លោកស្រី......** **អភិបាលរងខេត្ត** ទទួលជួយអភិបាលខេត្ត លើកិច្ចការសាធារណការនិងដឹកជញ្ជូន កិច្ចការនគរូបនីយកម្ម សំណង់ និងសុរិយោដី កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម ទឹកស្អាតនិងអង្គភាពអគ្គិសនី ធនធានទឹក ឧតុនិយមនិងធារាសាស្ត្រ ប្រៃសណីយ៍ និងទូរគមនាគមន៍ ។

៦. **លោក/លោកស្រី......** **អភិបាលរងខេត្ត** ទទួលជួយអភិបាលខេត្ត លើកិច្ចការវិនិយោគ កិច្ចការផែនការ អភិវឌ្ឍន៍ជនបទ កិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ កិច្ចការសុខាភិបាល បរិស្ថាន និងគ្រប់គ្រងកាកសំណល់រឹងនិងរាវ កិច្ចការសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងកិច្ចការព្រំដែន (ចំពោះខេត្តជាប់ព្រំដែន) ។

៧. **លោក/លោកស្រី......** **អភិបាលរងខេត្ត** ទទួលជួយអភិបាលខេត្ត លើកិច្ចការគ្រប់គ្រងធនធានមនុស្ស កិច្ចការការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការមុខងារសាធារណៈ កិច្ចការអប់រំ យុវជន និងកីឡា ។

ក្រៅពីភារកិច្ចដែលបានបែងចែកខាងលើ អភិបាលខេត្តអាចប្រគល់ភារកិច្ចបន្ថែមជូនអភិបាលរងខេត្ត ទៅតាមសំណូមពរការងារជាក់ស្តែងរបស់រដ្ឋបាលខេត្ត ។

**ប្រការ៥..**

ចំពោះរបៀបរបបធ្វើការងាររបស់គណៈអភិបាលខេត្ត ត្រូវអនុវត្តឱ្យបានស្របទៅតាមសេចក្តីណែនាំ លេខ............. ចុះថ្ងៃទី .......ខែ .............ឆ្នាំ ២០១០ ស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារ ជូនគណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក ។

**ប្រការ៦..**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេច នេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៧..**

នាយក នាយករងរដ្ឋបាលសាលាខេត្ត ប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត ទីចាត់ការ និងការិយាល័យចំណុះរចនាសម្ព័ន្ធសាលាខេត្ត អភិបាលក្រុង អភិបាលគ្រប់ស្រុក និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ០៤ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

.................... *ថ្ងៃទី ខែ ឆ្នាំ ២០១០*

**អភិបាលខេត្ត**

**ចម្លងជូន**
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *លេខាធិការដ្ឋាន គ.ជ.អ.ប*
- *ដូចប្រការ ៧*
- *ឯកសារ កាលប្បវត្តិ*

បានឃើញ និង ឯកភាព

*រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០១០*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខេត្ត.....................

សាលាក្រុង/ស្រុក...............

លេខ.................................

**គំរូសម្រាប់ក្រុងស្រុក**

# សេចក្តីសម្រេច

## ស្តីពី

## ការបែងចែកតួនាទី ភារកិច្ច និង របៀបរបបធ្វើការងារ

## ជូនគណៈអភិបាលក្រុង ស្រុក.............................

*******

## អភិបាលក្រុង ស្រុក...............

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញប្រកាសលេខ ៤២៧៤ ប្រ ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ
- យោងសេចក្តីណែនាំលេខ.............. ចុះថ្ងៃទី .........ខែ ............ឆ្នាំ ២០១០ ស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក
- យោងស្មារតីប្រជុំក្រុមប្រឹក្សាក្រុង/ស្រុក...........ចុះថ្ងៃទី............ខែ ..............ឆ្នាំ២០១០

# ស ម្រេ ច

**ប្រការ១..**

គណៈអភិបាលក្រុង/ស្រុក..................... ត្រូវគ្រប់គ្រង និងដឹកនាំដោយអភិបាលក្រុង/ស្រុក ០១រូប និង អភិបាលរង ចំនួន.........រូប ជាជំនួយការ ។

**ប្រការ២..**

អភិបាល និងអភិបាលរងក្រុង/ស្រុក ត្រូវរួមគ្នាដឹកនាំ គ្រប់គ្រងកិច្ចការរដ្ឋបាលដែនដី ការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម និង លើកកំពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ នៅក្នុងក្របខ័ណ្ឌ នៃភូមិសាស្ត្រក្រុង/ស្រុក ស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានដែលនៅជាធរមាន និង សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ។

**ប្រការ៣..**

អភិបាល និងអភិបាលរងក្រុង/ស្រុក ត្រូវបំពេញមុខងារ និងទទួលខុសត្រូវស្របទៅតាមលំដាប់ឋានានុក្រម និងអនុវត្តតួនាទី ភារកិច្ច ដែលបានបែងចែក ដូចមានក្នុងប្រការ ០៤ ។

អភិបាលរងក្រុង/ស្រុក ដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលក្រុង/ស្រុក លើភារកិច្ចនានាដែលបានប្រគល់ ហើយត្រូវរួមជាមួយអភិបាលក្រុង/ស្រុក ទទួលខុសត្រូវអំពីការសម្រេច និងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន ។

**ប្រការ៤..**

អភិបាល និង អភិបាលរងក្រុង/ស្រុក.......ត្រូវបានកំណត់នូវការបែងចែកតួនាទី ភារកិច្ចដូចខាងក្រោម ÷

**ក. ការបែងចែកភារកិច្ចសម្រាប់ក្រុង/ស្រុកដែលមានគណៈអភិបាលចំនួន ០៣រូប :**

១. **លោក ............** **អភិបាលក្រុង/ស្រុក...............** ទទួលបន្ទុកដឹកនាំការងាររួម និង ដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការងារនៅ **ការិយាល័យផែនការនិងគាំទ្រឃុំសង្កាត់ ឬការិយាល័យផែនការនិងគាំទ្រឃុំ សង្កាត់** កិច្ចការផែនការ វិនិយោគ អភិវឌ្ឍន៍ជនបទ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន កិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ និងជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

២. **លោក/លោកស្រី......** **អភិបាលរងក្រុង/ស្រុក** ទទួលជួយអភិបាលក្រុង/ស្រុក លើការងារ **ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ** និងទទួលជួយកិច្ចការព័ត៌មាន ស្ថិតិនិងអត្រានុកូលដ្ឋាន កិច្ចការនារីនិងកុមារ អប់រំ យុវជន និងកីឡា ទេសចរណ៍ វប្បធម៌ ធម្មការនិងសាសនា សុខាភិបាល កិច្ចការការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ កិច្ចការធនាគារ រតនាគារ ពន្ធដារ សាខាកាំកុងត្រូល គយនិងរដ្ឋាករ និងកិច្ចការលទ្ធកម្ម ។

៣. លោក/លោកស្រី...... **អភិបាលរងក្រុង/ស្រុក** ទទួលជួយអភិបាលក្រុង/ស្រុក លើការងារ**ការិយាល័យអភិវឌ្ឍក្រុងឬការិយាល័យអន្តរវិស័យ** និងទទួលជួយសាធារណការនិងដឹកជញ្ជូន កិច្ចការបរិស្ថាន កិច្ចការនគរូបនីយកម្ម សំណង់និងសុរិយោដី កិច្ចការសិទ្ធិមនុស្ស អង្គការក្រៅរដ្ឋាភិបាល គណបក្សនយោបាយ សមាគម កិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ កិច្ចការសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋបាលព្រៃឈើ រដ្ឋបាល ជលផល កិច្ចការពាណិជ្ជកម្ម ឧស្សាហកម្ម រ៉ែនិងថាមពល ទឹកស្អាត ធនធានទឹក ឧតុនិយម និងធារាសាស្ត្រ កិច្ចការប្រៃសណីយ៍ និងទូរគមនាគមន៍ ។

ក្រៅពីភារកិច្ចដែលបានបែងចែកខាងលើ អភិបាលក្រុង/ស្រុក អាចប្រគល់ភារកិច្ចបន្ថែមជូនអភិបាលរងក្រុង/ស្រុក ទៅតាមសំណូមពរការងារជាក់ស្តែងរបស់រដ្ឋបាលក្រុង/ស្រុក ។

**ខ. ការបែងចែកភារកិច្ចសម្រាប់ក្រុង/ស្រុកដែលមានគណៈអភិបាលចំនួន ០៤រូប ៖**

១. លោក ............ **អភិបាលក្រុង/ស្រុក**...............ទទួលបន្ទុកដឹកនាំការងាររួម និង ដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងកិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

២. លោក/លោកស្រី...... **អភិបាលរងក្រុង/ស្រុក** ទទួលជួយអភិបាលក្រុង/ស្រុក លើកិច្ចការព័ត៌មាន កិច្ចការស្ថិតិនិងអត្រានុកូលដ្ឋាន កិច្ចការនារីនិងកុមារ កិច្ចការសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល គណបក្សនយោបាយ សមាគម កិច្ចការការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារ រតនាគារ ពន្ធដារ សាខាកាំកុងត្រូល គយនិងរដ្ឋាករ និងកិច្ចការលទ្ធកម្ម ។

៣. លោក/លោកស្រី...... **អភិបាលរងក្រុង/ស្រុក** ទទួលជួយអភិបាលក្រុង/ស្រុក លើកិច្ចការបរិស្ថាន កិច្ចការសាធារណការនិងដឹកជញ្ជូន កិច្ចការនគរូបនីយកម្ម សំណង់ និងសុរិយោដី កិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ កិច្ចការកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល កិច្ចការពាណិជ្ជកម្ម ឧស្សាហកម្ម ទឹកស្អាត កិច្ចការធនធានទឹក ឧតុនិយម និងធារាសាស្ត្រ កិច្ចការប្រៃសណីយ៍និងទូរគមនាគមន៍ ។

៤. **លោក/លោកស្រី......** **អភិបាលរងក្រុង/ស្រុក** ទទួលជួយអភិបាលក្រុង/ស្រុក លើកិច្ចការផែនការ កិច្ចការវិនិយោគ កិច្ចការអភិវឌ្ឍន៍ជនបទ អប់រំ យុវជន និងកីឡា ទេសចរណ៍ វប្បធម៌ សាសនា សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង កិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ ។

ក្រៅពីភារកិច្ចដែលបានបែងចែកខាងលើ អភិបាលក្រុង/ស្រុក អាចប្រគល់ភារកិច្ចបន្ថែមជូនអភិបាលរង ក្រុង/ស្រុក ទៅតាមសំណូមពរការងារជាក់ស្តែងរបស់រដ្ឋបាលក្រុង/ស្រុក ។

**គ. ការបែងចែកភារកិច្ចសម្រាប់ក្រុង/ស្រុកដែលមានគណៈអភិបាលចំនួន ០៥រូប :**

១. **លោក ............** **អភិបាលក្រុង/ស្រុក................**ទទួលបន្ទុកដឹកនាំការងាររួម និង ដឹកនាំផ្ទាល់លើ ការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និង កិច្ចការ ប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

២. **លោក/លោកស្រី......** **អភិបាលរងក្រុង/ស្រុក** ទទួលជួយអភិបាលក្រុង/ស្រុក លើកិច្ចការសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ កិច្ចការធនាគារ រតនាគារ ពន្ធដារ សាខាកាំកុងត្រូល គយនិងរដ្ឋាករ កិច្ចការលទ្ធកម្ម និងកិច្ចការសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ។

៣. **លោក/លោកស្រី....** **អភិបាលរងក្រុង/ស្រុក** ទទួលជួយអភិបាលក្រុង/ស្រុក លើកិច្ចការព័ត៌មាន កិច្ចការនារីនិងកុមារ កិច្ចការសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល គណបក្ស នយោបាយ សមាគម កិច្ចការការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការអប់រំ យុវជននិងកីឡា កិច្ចការស្ថិតិនិងអត្រានុកូលដ្ឋាន។

៤. **លោក/លោកស្រី......** **អភិបាលរងក្រុង/ស្រុក** ទទួលជួយអភិបាលក្រុង/ស្រុក លើកិច្ចការសាធារណការ និងដឹកជញ្ជូន កិច្ចការបរិស្ថាន កិច្ចការនគរូបនីយកម្ម សំណង់និងសុរិយោដី កិច្ចការ កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ពាណិជ្ជកម្ម ឧស្សាហកម្ម ទឹកស្អាត កិច្ចការធនធានទឹក ឧតុនិយមនិងធារាសាស្ត្រ ប្រៃសណីយ៍ និងទូរគមនាគមន៍ និងកិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ។

៥. **លោក/លោកស្រី......** **អភិបាលរងក្រុង/ស្រុក** ទទួលជួយអភិបាលក្រុង/ស្រុក លើកិច្ចការផែនការ កិច្ចការវិនិយោគ អភិវឌ្ឍន៍ជនបទ ទេសចរណ៍ វប្បធម៌ ធម្មការនិងសាសនា សុខាភិបាល និងកិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ ។

ក្រៅពីភារកិច្ចដែលបានបែងចែកខាងលើ អភិបាលក្រុង/ស្រុក អាចប្រគល់ភារកិច្ចបន្ថែមជូនអភិបាលរង ក្រុង/ស្រុក ទៅតាមសំណូមពរការងារជាក់ស្តែងរបស់រដ្ឋបាលក្រុង/ស្រុក ។

**ប្រការ៥..**

ចំពោះរបៀបរបបធ្វើការងាររបស់គណៈអភិបាលក្រុង/ស្រុក ត្រូវអនុវត្តឱ្យបានស្របទៅតាមសេចក្តីណែនាំ លេខ............. ចុះថ្ងៃទី .......ខែ .............ឆ្នាំ ២០១០ ស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារ ជូនគណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក ។

**ប្រការ៦..**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេច នេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៧..**

នាយករដ្ឋបាលសាលាក្រុង/ស្រុក ប្រធានការិយាល័យ អង្គភាពជុំវិញក្រុង/ស្រុក ការិយាល័យចំណុះរចនាសម្ព័ន្ធសាលាក្រុង/ស្រុក និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ០៤ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

.................... *ថ្ងៃទី ខែ ឆ្នាំ ២០១០*

**អភិបាលក្រុង/ស្រុក**

**កន្លែងទទួល**

- *ក្រសួងមហាផ្ទៃ*
- *ទីស្តីការ អង្គភាពជំនាញជុំវិញខេត្ត.......*
- *លេខាធិការដ្ឋាន គ.ជ.អ.ប*
- *ដូចប្រការ ៧*
- *ឯកសារ កាលប្បវត្តិ*

បានឃើញ និង ឯកភាព

...................., *ថ្ងៃទី ខែ ឆ្នាំ ២០១០*

**អភិបាលខេត្ត......**